# លក្ខខណ្ឌ និង ដំណើរការស្នើរសុំអាហាររូបករណ៍

## គោលបំណង

ដើម្បីផ្តល់អាហារូបករណ៍និងជំនួយជាអាហារូបករណ៍ដល់និស្សិតដែលមានតម្រូវការផ្នែកហិរញ្ញវត្ថុ អោយបានចូលរៀននៅតាមសាលារដ្ឋ / ឯកជន (ទាំងថ្នាក់បឋមសិក្សា,អនុវិទ្យាល័យ ,វិទ្យាល័យ, សាកលវិទ្យាល័យ, និងថ្នាក់ក្រោយបញ្ចប់ការសិក្សា) ។

## លក្ខខណ្ឌនៃការដាក់ពាក្យះ

១. សម្រាប់បេក្ខជនដែលមកដាក់ពាក្យអាហារូបករណ៍លើកដំបូងទាំងអស់ ត្រូវមានលិខិតបញ្ជាក់ជីវភាពពីមេភូមិ (ប័ណ្ណក្រីក្រ) និង និងលិខិតបញ្ជាក់ពីគ្រូគង្វាលដើម្បីបញ្ជាក់ពីតម្រូវការ ឬការខ្វះខាតផ្នែកហិរញ្ញវត្ថុរបស់ពួកគេ។

ក. ចំពោះនិស្សិតដែលកំពុងតែទទួលបាននូវអាហារូករណ៍ សូមភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់ជីវភាពពីមេភូមិ និង លិខិតបញ្ជាក់ពីគ្រូគង្វាល ឬពីអ្នកដែលណែនាំមក នៅពេលដែលពួកគេបញ្ចប់ ការសិក្សាពីមួយ កម្រិតទៅមួយ កម្រិតទៀត (ពីថ្នាក់បឋមទៅអនុវិទ្យាល័យ/ពីអនុវិទ្យាល័យទៅវិទ្យាល័យ/ ពីវិទ្យាល័យទៅមហាវិទ្យាល័យ)

២. សម្រាប់សិស្ស/និស្សិតដែលទទួលបានអាហាររូបករណ៍ទាំងអស់ តម្រូវអោយនាំយកនូវព្រឹត្តិបត្រពិន្ទុប្រចាំឆ្នាំនីមួយៗ ឬ ឆមាសនីមួយៗដែលបានជាប់គ្រប់មុខវិជ្ជា ឬ ឡើងថ្នាក់ ដើម្បីមកបន្តទទួលនូវអាហាររូបករណ៍សម្រាប់ឆ្នាំសិក្សាបន្ទាប់។

ខ. ក្នុងករណីដែលសិស្ស/និស្សិតដែលមិនទទួលបាននូវពិន្ទុល្អ (ធ្លាក់)នូវមុខវិជ្ជាណាមួយ ពួកគេនឹងទទួលបាននូវលិខិតព្យួរអាហារូបករណ៍ជាបណ្តោះអាសន្ន។ ប្រសិនបើពួកគេនៅតែមានពិន្ទុធ្លាក់ទៀតសម្រាប់ឆមាសបន្ទាប់ និស្សិតនឹងត្រូវបញ្ឈប់ពីកម្មវិធីផ្តល់អាហារូបករណ៍របស់យើងតទៅ។

៣. សម្រាប់សិស្សដែលបញ្ចប់ការសិក្សាតាមកម្រិតនីមួយៗ ពីកម្រិតបឋម ទៅអនុវិទ្យាល័យ ពីអនុវិទ្យាល័យទៅវិទ្យាល័យ ពីវិទ្យាល័យទៅមហាវិទ្យាល័យ ពួកគេត្រូវសរសេរសំណេរពីគោលបំណងដែលគេចង់ធ្វើនៅពេលអនាគតនឹងយកមក ប្រគល់ជូនដល់គណកម្មការអាហារូបករណ៍ (មិនមែនចម្លងពីសំណេរចាស់)។

៤. សម្រាប់និស្សិតដែលទើបតែចូលរៀននៅមហាវិទ្យាល័យ ពួកគេត្រូវតែប្រលងជាប់ថ្នាក់មធ្យមសិក្សាទុតិយភូមិ និងត្រូវភ្ជាប់មកជាមួយនូវវិញ្ញាបនបត្របណ្តោះអាសន្នមកជាមួយនឹងពាក្យស្នើសុំអាហារូបករណ៍

៥. មិនអាចមានសមាជិកលើសពី ២នាក់ នៅក្នុងគ្រួសារតែមួយអាចដាក់ពាក្យស្នើសុំអាហារូបករណ៍បាន

## ដំណើរការនៃការផ្តល់អាហារូបករណ៍

- បេក្ខជនដែលដាក់ពាក្យស្នើសុំអាហារូបករណ៍ទាំងអស់ត្រូវបំពេញពាក្យសុំអាហារូបករណ៍ និង ត្រូវភ្ជាប់មកជាមួយនូវឯកសារដែលបានបញ្ជាក់ខាងលើ
- បេក្ខជនដែលដាក់ពាក្យស្នើសុំអាហារូបករណ៍សម្រាប់ថ្នាក់មហាវិទ្យាល័យទាំងអស់ត្រូវឆ្លងកាត់ការសម្ភាសពីគណកម្មាការផ្តល់អាហារូបករណ៍ជាមុនសិន
- គណកម្មាការផ្តល់អាហារូបករណ៍នឹងជូនដំណឹងត្រឡប់ទៅបេក្ខជនដែលបានដាក់ពាក្យស្នើសុំអាហារូបករណ៍វិញបន្ទាប់ពីការត្រួតពិនិត្យនូវពាក្យស្នើសុំអាហារូបករណ៍ (និងការសម្ភាសរួចរាល់)

**កាលបរិច្ឆេទនៃការដាក់ពាក្យ**

- សម្រាប់សិស្ស ឬ និស្សិតថ្មី ដែលដាក់ពាក្យស្នើសុំអាហាររូបករណ៍ជាលើកដំបូងសូមបំពេញពាក្យស្នើសុំអាហារូបករណ៍សម្រាប់ឆ្នាំសិក្សា ២០២០-២០២១ សូមដាក់ពាក្យមកកាន់ការិយាល័យ យូ អឹម ស៊ី UMC ចាប់ពីថ្ងៃទី ០១ ខែ កក្កដា ដល់ ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០២០។
- សម្រាប់សិស្ស ឬ និស្សិតចាស់ ដែលធ្លាប់ទទួលបានអាហារូបករណ៍រួចមកហើយ សូមស្នើសុំប្រាក់សម្រាប់ផ្គត់ផ្គង់ការសិក្សានៅការិយាល័យ យូ អឹម ស៊ី UMC ចាប់ពីថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០២០ រហូតដល់ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០២០។